**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៦ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីសម្រួល ការផលិតស្នាដៃភាពយន្តក្នុងព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងឧស្សាហកម្មភាពយន្ត
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ



www.pheakdeylaw.com

**សម្រេច**

**ប្រការ១ ._**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីសម្រួលការផលិតស្នាដៃភាពយន្តក្នុងព្រះរាជាណាចក្រកម្ពុជា ដែលសរសេរជាអក្សរកាត់ថា **គ.ស.ផ.ភ.** ដើម្បីជួយសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ សំដៅអនុវត្តគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌ ក្នុងការប្រើប្រាស់សក្តានុពលវប្បធម៌ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

**ប្រការ២ ._**

**គ.ស.ផ.ភ.** មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- លោកជំទាវ **ភឿង សកុណា** | រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ប្រធាន |
| ២- ឯកឧត្តម **សោម សុគន្ធ** | រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៣- ឯកឧត្តម **ថ្នាក់ សុខុម** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤- ឯកឧត្តម **ម៉ៅ អាយុទ្ធ** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | អនុប្រធាន |
| ៥- ឯកឧត្តម **ហ៊ុយ វណ្ណៈ** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៦- ឯកឧត្តម **ឈុន សុភាព** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៧- ឯកឧត្តម **ឃុត ចាន់ដារ៉ា** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៨- ឯកឧត្តម **គង់ កន្ធារ៉ា** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ៩- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | | សមាជិក |
| ១០- ឯកឧត្តម **ស៊ុំ ម៉ាប់** | អគ្គនាយកអាជ្ញាធរជាតិអប្សរា | សមាជិក |
| ១១- ឯកឧត្តម **គង់ ពុទ្ធិការ** | អគ្គនាយកអាជ្ញាធរជាតិព្រះវិហារ | សមាជិក |
| ១២- ឯកឧត្តម **ផាន់ ណាឌី** | អគ្គនាយកអាជ្ញាធរជាតិសំបូរព្រៃគុក | សមាជិក |
| ១៣- ឯកឧត្តម **ហាប់ ទូច** | អគ្គនាយកបច្ចេកទេសវប្បធម៌ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ១៤- លោក **អោ សៀម** | ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៥- លោក **ម៉ូរ ម៉ុនណារ៉ា** | តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៦- លោក **ហេង ណារិទ្ធ** | តំណាងអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៧- លោក **ម៉ុក ឫទ្ធីគ្រី** | ប្រធាននាយកដ្ឋានសិល្បៈភាពយន្តនិងផ្សព្វផ្សាយវប្បធម៌នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | លេខាធិការ។ |

**ប្រការ៣ ._**

**គ.ស.ផ.ភ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖



www.pheakdeylaw.com

- លើកគោលនយោបាយនិងយុទ្ធសាស្ត្រលើកទឹកចិត្តក្នុងការទាក់ទាញការផលិតភាពយន្ត សំដៅជំរុញព្រះរាជាណាចក្រកម្ពុជាឲ្យក្លាយជាដែនដីនៃការថតភាពយន្តបរទេស
- ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីសម្រួលដល់ការផលិតភាពយន្ត
- សម្របសម្រួលលើការស្នើសុំថតភាពយន្តតាមករណីពាក់ព័ន្ធនឹងក្រសួង ស្ថាប័ន
- តាមដានការអនុវត្តនិងពិនិត្យលើរបាយការណ៍អំពីស្ថានភាពនៃការផលិតភាពយន្ត
- ដោះស្រាយវិវាទផ្សេងៗពាក់ព័ន្ធនឹងដំណើរការថតភាពយន្ត
- រាយការណ៍ជូនរាជរដ្ឋាភិបាលពីដំណើរការរបស់ **គ.ស.ផ.ភ.**។

**ប្រការ៤ ._**

អនុប្រធាននិងសមាជិកគណៈកម្មការអន្តរក្រសួងដូចមានចែងក្នុងប្រការ២ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៥ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៣ រោច ខែ ពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com